**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# អ្នកជំនាញផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមានប្រសាសន៍ថា ការរំលោភយកដីធ្លីនៅអាស៊ីធ្វើឲ្យជនជាតិដើមភាគតិចផ្លាស់ទីលំនៅ និងបំផ្លាញបរិស្ថាន

**ទីក្រុងហ្សឺណែវ (ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០)** - អ្នកជំនាញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មានប្រសាសន៍ថា ជនជាតិដើមភាគតិចនៅអាស៊ី កំពុងប្រឈមនឹងការផ្លាស់ទីលំនៅជាច្រើន ការបំផ្លាញបរិស្ថាន និងការកើនឡើងនូវភាពក្រីក្រ ដោយសារការរំលោភយកដីធ្លី។

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនជាតិដើមភាគតិច លោក **ហ្វ្រង់ស៊ីស្កូ កាលីសៃ** មានប្រសាសន៍ថា "គម្រោងអភិវឌ្ឍន៍ខ្នាតធំ រួមមាន ទំនប់វារីអគ្គិសនី ការរុករករ៉ែ ការដាំដំណាំតែមួយមុខ និងការកាប់ព្រៃឈើ កំពុងតែកើនឡើងនៅក្នុងតំបន់ បង្កការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅពេលជនជាតិដើមភាគតិចបាត់បង់ដីប្រពៃណី និងធនធានរបស់ពួកគេ" លោកមានប្រសាសន៍ដូច្នេះនៅកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់ ដែលរៀបចំឡើងដោយបុព្វការីរបស់លោក នៅទីក្រុងបាងកក។ បញ្ហានេះនឹងត្រូវបង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅខែកញ្ញានេះ។

"រដ្ឋទាំងឡាយត្រូវចាត់វិធានការដើម្បីទប់ស្កាត់អំពើហឹង្សា និងការដាក់ទោសដល់ជនជាតិដើមភាគតិច ដែលកើតឡើងពីការអនុវត្តសិទ្ធិ និងការការពារដីធ្លី និងដែនដីរបស់ពួកគេ។ ការពង្រឹងបទប្បញ្ញត្តិរបស់ក្រុមហ៊ុនឯកជនគឺចាំបាច់ណាស់"។

ជនជាតិដើមភាគតិចខ្វះការទទួលស្គាល់តាមផ្លូវច្បាប់អំពីស្ថានភាពរបស់ពួកគេ ហើយមានការខកខានជាច្រើនលើកច្រើនគ្រាមិនបានការពារដីធ្លី និងគោរពសិទ្ធិរបស់ពួកគេក្នុងការចូលរួម និងធ្វើការពិគ្រោះយោបល់ជាមួយពួកគេក្នុងការសម្រេចចិត្តទាំងឡាយណាដែលប៉ះពាល់ដល់ពួកគេ។

នៅទូទាំងតំបន់ ជនជាតិដើមភាគតិច ជាពិសេសស្ត្រី និងជនពិការ នៅតែបន្តត្រូវបានគេរើសអើង និងបាត់បង់ឱកាស។ សម្រាប់រដ្ឋទាំងឡាយដែលដាក់អនុវត្តសកម្មភាពនៃការសន្យាអភិវឌ្ឍន៍របស់ពួកគេដោយមិនទុកនរណាម្នាក់ចោលនោះ កាតព្វកិច្ចចំពោះជនជាតិដើមភាគតិចត្រូវស្ថិតនៅជួរមុខ ហើយឆ្លុះបញ្ចាំងនៅក្នុងវិធានការគោលនយោបាយ និងនៅក្នុងការបែងចែកធនធាន។

អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ថា "ការលើកស្ទួយសិទ្ធិជនជាតិដើមភាគតិច និងទម្លាប់អនុវត្តជាលក្ខណៈប្រពៃណីរបស់ពួកគេ គឺជាគន្លឹះដើម្បីទទួលបានការអភិវឌ្ឍប្រកបដោយចីរភាព ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងការអភិរក្សជីវៈចម្រុះ"។

"ចប់"

សូមមើលរបាយការណ៍ស្តីពីកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់នៅទីនេះ"។

**លោក** José Francisco CALÍ *TZAY* **(ក្វាតេម៉ាឡា)** គឺជាអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនជាតិដើមភាគតិច។ លោកគឺជនជាតិដើមម៉ាយ៉ា មកពីប្រទេសក្វាតេម៉ាឡា ដែលមានបទពិសោធន៍ការពារសិទ្ធិជនជាតិដើមភាគតិចទាំងនៅប្រទេសក្វាតេម៉ាឡា និងនៅកម្រិតអង្គការសហប្រជាជាតិ ទាំងនៅអង្គការរដ្ឋអាមេរិក (The OAS )។ លោក Calí Tzay គឺជាស្ថាបនិក និងជាសមាជិកនៃអង្គការជនជាតិដើមភាគតិចផ្សេងគ្នា និងជាឯកអគ្គរដ្ឋទូតនៃប្រទេសក្វាតេម៉ាឡា ប្រចាំនៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ គាត់គឺជានាយកសិទ្ធិមនុស្សនៅក្រសួងការបរទេសប្រទេសក្វាតេម៉ាឡា។ សមាជិកនៃគណៈកម្មការប្រធានាធិបតីប្រឆាំងនឹងការរើសអើង និងប្រកាន់ពូជសាសន៍ប្រឆាំងនឹងជនជាតិដើមនៅក្វាតេម៉ាឡា (CODISRA) និងជាប្រធានកម្មវិធីសំណងជាតិសម្រាប់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុង។ លោក Cali Tzay គឺជាប្រធានគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ដែលជាស្ថាប័នសន្ធិសញ្ញាមួយ ដែលលោកត្រូវបានគេបោះឆ្នោតជ្រើសរើសក្នុងរយៈពេល ៤ ឆ្នាំជាប់ៗគ្នាក្នុងរយៈពេល ៤ ឆ្នាំ។

*អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេហៅថានីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេសដែលជាស្ថាប័នជំនាញឯករាជ្យធំបំផុតនៅក្នុងប្រព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិគឺជាឈ្មោះទូទៅនៃយន្តការស្វែងរក និងតាមដានព័ត៌មានឯករាជ្យរបស់ក្រុមប្រឹក្សាដែលដោះស្រាយបញ្ហាទាំងនៅក្នុងប្រទេសជាក់លាក់ ឬបញ្ហាតាមវិស័យនានានៅលើពិភពលោក។ អ្នកជំនាញនីតិវិធីពិសេសធ្វើការដោយស្ម័គ្រចិត្ត។ ពួកគេមិនមែនជាបុគ្គលិករបស់អង្គការសហប្រជាជាតិហើយមិនទទួលបានប្រាក់ខែសម្រាប់ការងាររបស់ពួកគេ។ ពួកគេឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយហើយបំពេញការងារតាមសមត្ថភាពបុគ្គលរបស់ពួកគេ។*

សម្រាប់ព័ត៌មានបន្ថែម និងសំណូមពររបស់ប្រព័ន្ធផ្សព្វផ្សាយសូមទាក់ទង Christine Evans តាមទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៩៧ / អ៊ីមែល៖ cevans@ohchr.org) Claire Morclette តាមទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៤ ៣៧ / អ៊ីមែល៖ cmorclette@ohchr.org) ឬសរសេរទៅកាន់ indigenous@ohchr.org

សម្រាប់ការសាកសួរព័ត៌មានទាក់ទងនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់អង្គការសហប្រជាជាតិសូមទាក់ទងលោក Jeremy Laurence តាមទូរស័ព្ទ (+ ៤១ ២២ ៩១៧ ៧៥៧៨ / អ៊ីមែល៖ jlaurence@ohchr.org)
តាមដានព័ត៌មានទាក់ទងនឹងអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់ អ. ស. ប នៅលើ Twitter៖ @UN_SPExperts។

តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងរស់នៅមែនទេ?
ដូច្នេះ អ្នកត្រូវក្រោកឈរឡើងដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។
#Standup4humanrights
ហើយចូលមើលទំព័រវេបសាយតាមរយៈ http://www.standup4humanrights.org